# បទឧទ្ទេសនាម
## របស់
## អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## ក្នុងសម័យប្រជុំពេញអង្គនៃរដ្ឋសភា ដើម្បីពិភាក្សា និង អនុម័ត សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩

***រដ្ឋសភា, ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១៨***

ខ្ញុំបាទសូមគោរព ៖

- សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់;
- ឯកឧត្តមបណ្ឌិតអនុប្រធានទី ១ នៃរដ្ឋសភា;
- លោកជំទាវអនុប្រធានទី ២ នៃរដ្ឋសភា;
- សម្តេច, ឯកឧត្តម, លោកជំទាវ, សមាជិក, សមាជិកា, នៃរដ្ឋសភា និង អង្គរដ្ឋសភា ដ៏ឧត្តុង្គឧត្តម!

តាងនាមរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំបាទសូមសំដែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា, គណៈអចិន្ត្រៃយ៍នៃរដ្ឋសភា, គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និង សវនកម្ម ព្រមទាំងគណៈកម្មការពាក់ព័ន្ធទាំងអស់នៃរដ្ឋសភា, និង អង្គរដ្ឋសភាទាំងមូល, ដែលបានចាត់ការយ៉ាងរួសរាន់ និង អនុម័តដាក់ **សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩** ចូលក្នុងរបៀបវារៈរបស់ខ្លួន ក្នុងសម័យប្រជុំពេញអង្គរដ្ឋសភា នាថ្ងៃនេះ ។ អាស្រ័យដោយរាជរដ្ឋាភិបាលបានរៀបចំសេចក្តីថ្លែងហេតុពិស្តារមួយគោរពជូន **សម្តេចចក្រីប្រធានរដ្ឋសភា** និង អង្គសភារួចហើយ, ហើយ **ឯកឧត្តមបណ្ឌិតរដ្ឋ ជាម យៀប** ក្នុងនាមគណៈកម្មការទី ២ នៃរដ្ឋសភា ក៏បានរាយការណ៍លម្អិតបន្ថែមទៀតជូនអង្គរដ្ឋសភាអម្បាញ់មិញនេះដែរ រួមទាំងអំពីមូលដ្ឋានគតិយុត្ត, ទិដ្ឋភាពរួម, និង រចនាសម្ព័ន្ធនៃសេចក្តីព្រាងច្បាប់នេះផង; ដូច្នេះ នៅពេលនេះ ខ្ញុំបាទសូមអនុញ្ញាតធ្វើបទឧទ្ទេសនាមដោយសង្ខេបខ្លះដើម្បីចំណេញពេល ។ យ៉ាងណាក៏ដោយ,

ខ្ញុំបាទគោរពសុំការអធ្យាស្រ័យជាមុន ចំពោះករណីដែលខ្ញុំបាទអាចថ្លែងឡើងវិញ ក្នុងគោលដៅគូសបញ្ជាក់ ឬ សង្កត់ធ្ងន់បន្ថែម ឬ សម្រួចបន្ថែម នូវចំណុចមួយចំនួននៅក្នុងបទឧទ្ទេស-នាមនេះ ដែលអាចជាន់គ្នានឹងអ្វីដែល **ឯកឧត្តមបណ្ឌិតរដ្ឋ ជាម យៀប** បានរាយការណ៍ជូនអង្គរដ្ឋសភាមុននេះ ។

## I- អំពីបរិការណ៍រួមនៃការរៀបចំថវិកាឆ្នាំ ២០១៩

អាស្រ័យដោយ, **ឯកឧត្តមបណ្ឌិតរដ្ឋ ជាម យៀប** បានជម្រាបជូនអង្គសភារួចហើយ អំពីបរិការណ៍នយោបាយ និង គោលដៅផ្នែកគោលនយោបាយនៃការរៀបចំសេចក្តីព្រាង-ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ ខ្ញុំសូមមិនជម្រាបជូនឡើងវិញទេ, ប៉ុន្តែខ្ញុំសូមគូសបញ្ជាក់បន្ថែមថា នៅក្នុងរយៈពេលមធ្យមខាងមុខ, ក្នុងឋានៈជាប្រទេសចំណូលមធ្យមកម្រិតទាប, ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជានឹងឈានដល់ដំណាក់កាលប្រែប្រួលថ្មីមួយទៀត ជាពិសេសចាប់ពីពេលនេះតទៅមុខ ៥ ឆ្នាំ ទៀត ដែលជាអន្តរកាលឆ្ពោះទៅសម្រេចបាននូវឋានៈ ជា "ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០" ។ ក្នុង-ក្របខ័ណ្ឌនេះ, កម្ពុជាត្រូវតែមានប្រព័ន្ធរដ្ឋបាលសាធារណៈមួយដែលកាន់តែស្អាតស្អំ ឆ្លាតវៃ និង មានសមត្ថភាពខ្លាំងពូកែ (A Clean, Smart and Strong Government) ដើម្បីអាចដោះស្រាយបញ្ហាសង្គម និង សេដ្ឋកិច្ច ប្រកបដោយប្រសិទ្ធភាពខ្ពស់ សម្រាប់ទ្រទ្រង់ដល់ការផ្លាស់ប្តូររចនាសម្ព័ន្ធនៃសេដ្ឋកិច្ចកម្ពុជា ។

ជាការពិត, រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា បានបញ្ចប់បេសកកម្មជាប្រវត្តិ-សាស្ត្ររបស់ខ្លួន ប្រកបដោយភាពជោគជ័យដ៏ត្រចះត្រចង់ និង សម្រេចបាននូវសមិទ្ធផលធំៗជាច្រើនជូនប្រទេសជាតិ និង ប្រជាជន ដូចបានលម្អិតជូនរួចហើយនៅក្នុងអត្ថបទពិស្តារនៃសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់; ប៉ុន្តែអ្វីដែលសំខាន់ជាងនេះទៀត សម្រាប់រយៈ-ពេល ៥ ឆ្នាំខាងមុខ, កម្ពុជាត្រូវបន្តរក្សាឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាប្រមាណ ៧% ក្នុងមួយឆ្នាំ ដើម្បីបង្កើតការងារប្រកបដោយគុណភាពសម្រាប់យុវជនផង និង ឆ្លើយ-តបបាន ប្រកបដោយប្រសិទ្ធភាព ចំពោះក្តីរំពឹងទុករបស់ប្រជាជនដែលបន្តកើនឡើងជាលំដាប់ផង ។ ក្តីរំពឹងរបស់ប្រជាជនយើង គឺចង់បាននូវសេវាសាធារណៈសំខាន់ៗប្រកបដោយគុណភាព ជាពិសេស ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, សេវាអប់រំ, សុខាភិបាល, និង សេវាមូលដ្ឋានចាំបាច់ផ្សេងទៀត, រួមទាំង របបសន្តិសុខសង្គម និង ការធានានូវសុខុមាលភាពរបស់ប្រជា-ជនទូទៅ ក៏ដូចជាការធានាសុវត្ថិភាពចំណូល ជាពិសេស សម្រាប់ប្រជាជនងាយរងគ្រោះ ។

ចំពោះទិដ្ឋភាពក្រៅប្រទេស, ស្ថានភាពភូមិសាស្ត្រនយោបាយពិភពលោកដែលកំពុង-តែវិវត្តក្នុងក្របខ័ណ្ឌពហុប៉ូលនោះ ក៏កាន់តែមានភាពស្មុគស្មាញឡើងៗ ហើយស្ថានភាពសេដ្ឋកិច្ចពិភពលោក និង តំបន់ ក៏នៅបន្តស្ថិតនៅក្នុងភាពមិនប្រាកដប្រជានៅឡើយ

ដោយសារសង្គ្រាមពាណិជ្ជកម្មដែលអាចនឹងនាំទៅដល់វិបត្តិរូបិយវត្ថុ និង ហិរញ្ញវត្ថុថែមទៀត ។ ពិតណាស់ថា, កម្ពុជាដែលជាប្រទេសមានសេដ្ឋកិច្ចបើកចំហរខ្លាំង និង ទទួលបានការរីក-ចម្រើនដោយសារសកលភាវូបនីយកម្ម អាចនឹងទទួលរងនូវផលប៉ះពាល់អវិជ្ជមានមួយចំនួន, ដោយមិនទាន់គិតទៅដល់ផលប៉ះពាល់បណ្តាលមកពីការឡើងថ្លៃប្រេង ព្រមទាំងលទ្ធភាពនៃការឡើងថ្លៃ និង ការដំឡើងអត្រាការប្រាក់ដុល្លារអាមេរិក ។ ក៏ប៉ុន្តែជាមួយគ្នានេះ, កម្ពុជាក៏អាចនឹងទទួលបាននូវកាលានុវត្តភាពមួយចំនួនវិញដែរ ដែលប្រការនេះអាស្រ័យលើសមត្ថ-ភាព និង លទ្ធភាពនៃការចេះបត់បែន និង តាមទាន់សភាពការណ៍ប្រែប្រួលក្នុងតំបន់ និង ពិភពលោក ដើម្បីបញ្ចៀស និង សម្រាលនូវផលប៉ះពាល់ជាអវិជ្ជមានទាំងឡាយ ដែលអាចកើតមានឡើងជាយថាហេតុ; ក៏ដូចជាការចេះប្រើប្រាស់លក្ខខណ្ឌអំណោយផលទាំងឡាយសម្រាប់លើកកម្ពស់ប្រសិទ្ធភាព និង ភាពប្រកួតប្រជែងសេដ្ឋកិច្ច, និង កែលម្អបរិស្ថាន-វិនិយោគ សម្រាប់ទទួល និង ទាក់ទាញបន្ថែមនូវការវិនិយោគ និង ធុរកិច្ច ដែលអាចនឹងហូរចេញពីតំបន់មានជម្លោះពាណិជ្ជកម្មចូលមកកាន់កម្ពុជា ។

*ក្នុងន័យនេះហើយដែលរាជរដ្ឋាភិបាលចាត់ទុកថា* ***ថវិកាឆ្នាំ ២០១៩ ដែលជាឆ្នាំទី ១ នៃនីតិកាលទី ៦ នៃរដ្ឋសភា ត្រូវតែជាថវិកាយុទ្ធសាស្ត្រនៃការរក្សាសមិទ្ធផលដែលសម្រេច-បានដោយលំបាក និង ការបន្តបុកគ្រឹះថ្មីៗ សម្រាប់គាំទ្រដល់ការសម្រេចបាននូវគោលដៅសំខាន់ៗនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី ៦ និង យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ដើម្បីបន្តរក្សាសន្តិភាព, ស្ថិរភាព, ក៏ដូចជាទ្រទ្រង់នូវដំណើរការវិវឌ្ឍ-ឈានឡើងរបស់កម្ពុជា, លើវិថីនៃការអភិវឌ្ឍប្រកបដោយគុណភាព និង ចីរភាព តទៅមុខឥតឈប់ឈរ ។***

## II- អំពីអតិក្រម និង គោលការណ៍សំខាន់ៗនៃការរៀបចំថវិកាឆ្នាំ ២០១៩

ឈរលើមូលដ្ឋានខាងលើនេះ, ថវិកាឆ្នាំ ២០១៩ ត្រូវបានរៀបចំឡើងដោយផ្អែកលើ <u>**គោលការណ៍គ្រឹះ**</u> ជាយុទ្ធសាស្ត្រសំខាន់ចំនួន ៤ ដែលក្នុងនោះរួមមាន ៖

(១)- ធានាសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧,០% ដើម្បីបន្តបង្កើតការងារថ្មីកាន់តែច្រើនជូនប្រជាជន ជាពិសេស សម្រាប់ស្រទាប់យុវជន, ផ្តល់លទ្ធភាពកាន់តែច្រើនឱ្យប្រជាជនទទួលបានប្រាក់ចំណូលកាន់តែខ្ពស់ ទន្ទឹមនឹងការខិតខំបង្កើនចំណូលថវិកាជាតិ;

(២)- ធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ជាពិសេស គ្រប់គ្រងបាននូវអតិផរណា និង ធានាស្ថិរភាពនៃអត្រាប្តូរប្រាក់ ព្រមទាំងស្ថិរភាពហិរញ្ញវត្ថុជាទូទៅ;

(៣)- បន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាជនតាមការសន្យា ក៏ដូចជា ការពង្រឹងគ្រឹះក្នុងការ-

កសាងស្ថាប័ន និង សមត្ថភាពនៃវិស័យសាធារណៈ ដើម្បីពង្រីកវិសាលភាព និង ពង្រឹងគុណភាពនៃសេវាសាធារណៈ និង សេវាយុត្តិធម៌;

(៤)- ផ្តល់ការលើកទឹកចិត្តដល់ក្រសួង-ស្ថាប័នណា ដែលអនុវត្តសកម្មភាពការងាររបស់ខ្លួន ប្រកបដោយបុរេសកម្ម និង មានសមិទ្ធកម្ម ឬ លទ្ធផលការងារល្អ ។

ជាមួយគ្នានេះ, ថវិកាឆ្នាំ ២០១៩ ក៏ផ្តោតជាពិសេសទៅលើ ៖

(១)-ការបន្តដំឡើងប្រាក់បៀវត្សជូនដល់មន្ត្រីរាជការ និង កងកម្លាំងប្រដាប់អាវុធ ដើម្បីបង្កើនកម្រិតជីវភាពរបស់មន្ត្រីរាជការ និង កងកម្លាំងប្រដាប់អាវុធឱ្យកាន់តែល្អប្រសើរ-ផង និង ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈផង។

(២)-ការវិនិយោគលើធនធានមនុស្ស និង ការជំរុញអនុវត្តនូវក្រុបខ័ណ្ឌគោលនយោ-បាយជាតិគាំពារសង្គម ២០១៧-២០២៥ របស់រាជរដ្ឋាភិបាល មានជាអាទិ៍ ការថែទាំសុខភាពមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និង អតីតយុទ្ធជន, របបថែទាំសុខភាពសម្រាប់កម្មករ និង របបឧបត្ថម្ភមាតុភាពសម្រាប់កម្មការិនី, របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ ។ល។

(៣)-ការកែទម្រង់សំដៅលើកកម្ពស់ និង កែលម្អប្រសិទ្ធភាព និង គុណភាពសេវា-សាធារណៈលើគ្រប់វិស័យ ដើម្បីឆ្លើយតបទៅនឹងសំណូមពរ និង សេចក្តីត្រូវការរបស់ប្រជាជន ។

(៤)-ការផ្តល់អាទិភាពលើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេស ផ្លូវ-ថ្នល់, អគ្គិសនី, និង ប្រព័ន្ធធារាសាស្ត្រស្រោចស្រព, ព្រមទាំងការជួសជុល និង ថែទាំហេដ្ឋា-រចនាសម្ព័ន្ធរូបវន្តដែលរងផលប៉ះពាល់ពីគ្រោះទឹកជំនន់ និង ជំនន់ទឹកភ្លៀងក្នុងឆ្នាំ ២០១៨ នេះ ដែលមានសារៈសំខាន់សម្រាប់ការបន្តជួយទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ច, ទាំងក្នុងរយៈពេលខ្លី, មធ្យម, និង វែង, ក៏ដូចជាសម្រាប់ការដោះស្រាយតម្រូវការជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ។

## III- **អំពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច**

នៅក្នុងផ្នែកនេះ, អាស្រ័យដោយអត្ថបទពិស្តារនៃសេចក្តីថ្លែងហេតុ បានគូសរំលេចរួច-ហើយអំពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០១៩, ក៏ដូចជាអំពីបញ្ហាប្រឈម និង ហានិភ័យ, ទាំងផ្នែកក្រៅប្រទេស, ទាំងផ្នែកក្នុងស្រុក, ព្រមទាំងអំពីវិធានការគោលនយោបាយមុតស្រួចមួយចំនួនដែលត្រូវបានដាក់ចេញ ដើម្បីធានារក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង ដើម្បីសម្រេចឱ្យបានកំណើនសេដ្ឋកិច្ចរឹងមាំ និង ប្រកបដោយចីរភាព; ដូចនេះ ដើម្បីចំណេញពេល, ខ្ញុំបាទសូមជម្រាបជូនជាសង្ខេបថា តាមការព្យាករណ៍ កំណើនសេដ្ឋកិច្ចកម្ពុជា នៅឆ្នាំ ២០១៩ នឹងអាចបន្តសម្រេចបានក្នុងអត្រា ៧,១% ដែលប្រហាក់ប្រហែលនឹង

កំណើនឆ្នាំ ២០១៨ ដែលធ្វើឱ្យ ផសស តាមថ្លៃបច្ចុប្បន្ន កើនឡើងដល់ **១០៩ ៨៩៤ ៩៤៩** លានរៀល, សមមូលនឹងប្រមាណ **២៧ ២២២** លានដុល្លារអាមេរិក, ហើយ ផសស សម្រាប់មនុស្សម្នាក់ត្រូវបានរំពឹងថានឹងកើនឡើងដល់ **១ ៧០៦** ដុល្លារអាមេរិក ធៀបនឹង **១ ៥៦៣** ដុល្លារអាមេរិក ក្នុងឆ្នាំ ២០១៨ ។ ជារួម, ផ្អែកលើសូចនាករម៉ាក្រូសេដ្ឋកិច្ចដូចបានកំណត់ខាងលើនេះ, យើងអាចនិយាយបានថា កម្ពុជានៅតែអាចបន្តសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ នៅក្នុងរយៈពេលខ្លី និង មធ្យមខាងមុខ, តែហានិភ័យនៃការថមថយនៃអត្រាកំណើនក៏កាន់តែកើន ។ លើសពីនេះទៀត, ភាពមិនប្រាកដប្រជានៃប្រព័ន្ធអនុគ្រោះពន្ធលើពាណិជ្ជកម្មអន្តរជាតិពីសំណាក់ដៃគូខ្លះ ក៏ជាបញ្ហាប្រឈមថ្មីមួយទៀតដែលត្រូវយកចិត្តទុកដាក់គ្រប់គ្រងឱ្យបានល្អ។

## IV- **អំពីក្របខ័ណ្ឌថវិកាឆ្នាំ ២០១៩**

ក្របខ័ណ្ឌថវិកាឆ្នាំ ២០១៩ ត្រូវបានរៀបចំដោយឈរលើអភិក្រម និង គោលការណ៍សំខាន់ៗដូចបានជម្រាបខាងលើ ក៏ដូចជាក្នុងក្របខ័ណ្ឌនៃកំណើនសេដ្ឋកិច្ចដែលត្រូវបានគ្រោងក្នុងរង្វង់ ៧% ព្រមជាមួយនឹងគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា ដែលតាមបច្ចេកស័ព្ទជាភាសាអង់គ្លេសហៅថា Fiscal Consolidation ។ ជារួម, ក្របខ័ណ្ឌថវិកាឆ្នាំ ២០១៩ ត្រូវបានកំណត់ដូចតទៅ៖

**១-ចំណូលក្នុងប្រទេស<u>ថវិការដ្ឋ</u> ឬ ហៅថាចំណូលក្នុងប្រទេស<u>ថវិកាជាតិ</u>** ត្រូវបានគ្រោងចំនួន ២១ ១៨៦ ២២៨ លានរៀល, សមមូលនឹងប្រមាណ ៥ ២៤៨ លានដុល្លារអាមេរិក, ត្រូវជា ១៩,២៨% នៃ ផសស, និង មានកំណើន ១៤,០% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ។ ក្របខ័ណ្ឌថវិកាឆ្នាំ ២០១៩ មានគោលដៅបង្កើនចំណូលចរន្តថវិការដ្ឋឱ្យបានស្មើនឹង ១៩,១០% នៃ ផសស ដែលមានកំណើនចំនួន ០,៥៧ ពិន្ទុភាគរយ នៃ ផសស ធៀបនឹងច្បាប់ឆ្នាំ ២០១៨, ពោលគឺនឹងសម្រេចបានលើស **គោលដៅនៃការប្រមូលចំណូលចរន្តថវិការដ្ឋ** ដែលបានកំណត់ឱ្យកើន ០,៥ ពិន្ទុភាគរយ នៃ ផសស ក្នុងមួយឆ្នាំ នៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ ២០១៤-២០១៨ ។

**២-ចំណាយសរុប<u>ថវិការដ្ឋ</u> ឬ ចំណាយសរុប<u>ថវិកាជាតិ</u>** ត្រូវបានគ្រោងចំនួន ២៧ ១៦៤ ៩៩៦ លានរៀល, សមមូលនឹងប្រមាណ ៦ ៧២៩ លានដុល្លារអាមេរិក, ត្រូវជា ២៤,៧២% នៃ ផសស, និង មានកំណើន ១១,៤% ធៀបនឹងច្បាប់ឆ្នាំ ២០១៨; ក្នុងនោះ ចំណាយចរន្តថវិការដ្ឋ ត្រូវបានគ្រោងចំនួន ១៧ ៩០៧ ៥៤៩ លានរៀល, សមមូលនឹងប្រមាណ ៤ ៤៣៦ លានដុល្លារអាមេរិក, ត្រូវជា ១៦,៣០% នៃ ផសស, និង មានកំណើន ១២,៣% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ។ ត្រង់នេះ, ខ្ញុំបាទសូមគូសបញ្ជាក់បន្ថែមថា គម្រោង <u>**ចំណាយបន្ទុកបុគ្គលិកសរុបនៃថវិការដ្ឋ**</u> ឆ្នាំ ២០១៩ នឹងមានទំហំ ៨ ៣៣៥ ១០២ លានរៀល,

សមមូលនឹងប្រមាណ ២ ០៦៥ លានដុល្លារអាមេរិក, ត្រូវជា **៧,៥៨% នៃ ផសស,** ឬ ស្មើនឹង **៤៦,៥៥%** នៃចំណាយចរន្តថវិការដ្ឋ ។ ទំហំចំណាយបន្ទុកបុគ្គលិកនេះឃើញថយចុះ ដោយសារការផ្ទេរការកត់ត្រាប្រាក់សោធននិវត្ត ចូលជាប្រភេទអត្ថប្រយោជន៍សង្គមនៃចំណាយមិនមែនបន្ទុកបុគ្គលិក ឱ្យស្របតាមឧត្តមានុវត្តជាអន្តរជាតិ ។ ប៉ុន្តែ, បើគិតបញ្ចូលប្រាក់សោធននិវត្តន៍ចំនួន ៨៦៨ ៨៧១ លានរៀល, ដែលសមមូលនឹងប្រមាណ ២១៥ លានដុល្លារអាមេរិក, នោះ ចំណាយបន្ទុកបុគ្គលិកនឹងឡើងដល់ ៨,៣៨% នៃ ផសស ឬ ស្មើនឹង ៥១,៤% នៃចំណាយចរន្តថវិការដ្ឋ ។ ការកើនឡើងចំណាយបន្ទុកបុគ្គលិកនេះ បានឆ្លុះបញ្ចាំងអំពីការផ្តល់អាទិភាពលើមនុស្សនៃគោលនយោបាយថវិការបស់រាជរដ្ឋាភិបាល ។

## V- អំពីគម្រោងចំណូល-ចំណាយថវិកាថ្នាក់ជាតិ

### ទី១- អំពីគម្រោងចំណូលថវិកាថ្នាក់ជាតិ

ថវិកាឆ្នាំ ២០១៩ មានគោលដៅបង្កើនចំណូលក្នុងប្រទេសថ្នាក់ជាតិ ឱ្យមានទំហំស្មើនឹង ១៩ ៧៨៦ ២៦០ លានរៀល, សមមូលនឹងប្រមាណ ៤ ៩០១ លានដុល្លារអាមេរិក, ត្រូវជា ១៨,០០% នៃ ផសស, គឺមានកំណើន ១២,២% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ។ ក្នុងក្របខ័ណ្ឌនេះ, ខ្លឹមសារពិស្តារនៃសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់នេះ បានរៀបរាប់រួចហើយ អំពីគោលដៅសម្រាប់ចំណូលចរន្ត, ទាំងគោលដៅចំណូលសារពើពន្ធ និង ចំណូលមិនមែនសារពើពន្ធ, ព្រមទាំងអំពីគោលដៅចំណូលមូលធន, ទាំងចំណូលមូលធនក្នុងប្រទេស និង ចំណូលមូលធនក្រៅប្រទេស ។ ដូច្នេះ, ដើម្បីបានចំណេញពេលវេលាខ្លះ, ខ្ញុំបាទសូមការអនុញ្ញាតមិនអធិប្បាយនូវចំណុចទាំងអស់នោះសាជាថ្មីឡើងវិញទេ ដោយគ្រាន់តែស្នើសុំគូសរំលេចបន្ថែមថា ដើម្បីរួមចំណែកសម្រេចគោលដៅចំណូលសារពើពន្ធដែលបានដាក់ចេញមកនេះ, អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា, និង អគ្គនាយកដ្ឋានពន្ធដារ, ដែលជាអង្គភាពប្រមូលចំណូលធំពីរ ស្ថិតក្រោមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុផ្ទាល់, ត្រូវខិតខំសម្រេចឱ្យបានតាមគោលដៅដែលត្រូវបានគ្រោង ដូចខាងក្រោម៖

- ចំណូលគយ និង រដ្ឋាករ ត្រូវបានគ្រោងចំនួន ៩ ០៩៤ ០០០ លានរៀល, សមមូលនឹងប្រមាណ ២ ២៥៣ លានដុល្លារអាមេរិក, ត្រូវជា ៨,២៨% នៃ ផសស, គឺមានកំណើន ៩,២% ធៀបនឹងច្បាប់ឆ្នាំ ២០១៨;
- ចំណូលពន្ធដារ ត្រូវបានគ្រោងចំនួន ៧ ៧៨៥ ០០០ លានរៀល, សមមូលនឹងប្រមាណ ១ ៩២៨ លានដុល្លារអាមេរិក, ត្រូវជា ៧,០៨% នៃ ផសស, គឺមានកំណើន ១៥,៤% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ។

## ទី២- អំពីគម្រោងចំណាយថវិកាថ្នាក់ជាតិ

## ក. ចំណាយចរន្តថវិកាថ្នាក់ជាតិ

### ក-១- <u>អំពីទិដ្ឋភាពរួមនៃចំណាយចរន្តថវិកាថ្នាក់ជាតិ</u>

ដូចបានគូសបញ្ជាក់នៅក្នុងអត្ថបទពិស្តារនៃសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់នេះ, ថវិកាថ្នាក់ជាតិឆ្នាំ ២០១៩ មានទិសដៅជាយុទ្ធសាស្ត្រកំណត់ចំណាយចរន្តឱ្យស្ថិតក្នុងកម្រិតចំនួន ១៦ ៨២៧ ២៨០ លានរៀល, សមមូលនឹងប្រមាណ ៤ ១៦៨ លានដុល្លារអាមេរិក, ត្រូវជា ១៥,៣១% នៃ ផសស, គឺមានកំណើន ១០,៦% ធៀបនឹងច្បាប់ឆ្នាំ ២០១៨, ដែលក្នុងនោះ ៖

**ក.១.១-<u>ចំណាយលើបន្ទុកបុគ្គលិក</u>** ត្រូវបានគ្រោងចំនួន ៧ ៨៦២ ៥៣៧ លានរៀល មានសមាមាត្រស្មើនឹង ៤៦,៧២% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ, ត្រូវជា ៧,១៥% នៃ ផសស, គឺថយចុះ ០,៧% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ។ ដូចបានបញ្ជាក់ពីខាងដើម, *ការ-ថយចុះនេះ គឺដោយសារចំណាយសម្រាប់របបសន្តិសុខសង្គមរបស់អតីតមន្ត្រីរាជការស៊ីវិល និង អតីតយុទ្ធជន ត្រូវបានផ្លាស់ប្តូរការកត់ត្រាពីក្នុងប្រភេទចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤) ទៅកត់ត្រាជាចំណាយអត្ថប្រយោជន៍សង្គម (ជំពូក ៦២) នៃប្រភេទចំណាយក្រៅបន្ទុកបុគ្គលិកវិញ ដើម្បីឱ្យស្របតាមឧត្តមានុវត្តជាអន្តរជាតិ* ។ ចំណាយបន្ទុកបុគ្គលិកនេះ ត្រូវ-បានគ្រោងសម្រាប់ ៖ (១)-ការដំឡើងបៀវត្សមូលដ្ឋានក្នុងអត្រា ១០% ដោយដំឡើងបៀវត្សមូលដ្ឋាន តាមតម្លៃឯកតាសន្ទស្សន៍ ២ ៣៤០ រៀល ដោយគិតចាប់ពីខែ មករា ដល់ខែ ធ្នូ ឆ្នាំ២០១៩; (២)-ការដំឡើងប្រាក់បំណាច់មុខងារបន្ថែមចំនួន ៣០ ០០០ រៀល ដល់មន្ត្រីរាជការស៊ីវិល និង កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទដែលមានប្រាក់បំណាច់មុខងារចាប់ពី ៧៥០ ០០០ រៀល ចុះក្រោម ដោយនឹងត្រូវអនុវត្តចាប់ពីខែ មេសា ដល់ខែ ធ្នូ ឆ្នាំ ២០១៩ ។ **ចំពោះការបើកប្រាក់បៀវត្សនឹងត្រូវធ្វើឡើងចំនួន ២ ដងក្នុងមួយខែ តាមប្រព័ន្ធធនាគារ** ចាប់ពីខែមករា ឆ្នាំ ២០១៩ ផងដែរ ។ ខ្ញុំបាទគោរពស្នើសុំសមាជិក-សមាជិកានៃអង្គរដ្ឋសភាដ៏ឧត្តុង្គឧត្តម មេត្តាយោងទៅសេចក្តីថ្លែងហេតុពិស្តារ ដើម្បីបានជ្រាបលម្អិតអំពីការផ្លាស់ប្តូរនៃស្ថានភាពបៀវត្សអប្បបរមារបស់មន្ត្រីរាជការគ្រប់ប្រភេទ នៅក្នុងឆ្នាំ ២០១៩ តាមរយៈវិធានការនេះ ។

ទន្ទឹមនឹងនេះ, រាជរដ្ឋាភិបាលបានគ្រោងថវិកាដោយឡែកមួយចំនួនផ្សេងទៀត រួមមាន៖

- ថវិកាចំនួន ២០ ប៊ីលានរៀល សម្រាប់ផ្តល់លទ្ធភាពដល់ក្រសួង-ស្ថាប័នអាចជ្រើសរើសមន្ត្រីមានសមត្ថភាព និង ជំនាញខ្ពស់ចូលបម្រើការងាររដ្ឋ ;

- ថវិកាចំនួន ៥០ ប៊ីលានរៀល ជាមូលនិធិថែទាំសុខភាពមន្ត្រីសាធារណៈ អតីត-មន្ត្រីរាជការ និង អតីតយុទ្ធជន ដើម្បីរ៉ាប់រងលើការទ្រទ្រង់ថែទាំសុខភាពមន្ត្រី-សាធារណៈ ;
- ថវិកាចំនួន ៦ ប៊ីលានរៀល ដើម្បីទ្រទ្រង់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ នៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាលផងដែរ ។

ចំពោះប្រាក់សោធននិវត្តន៍ ក៏ត្រូវបានគ្រោងថវិកាចំនួន ៦០ ប៊ីលានរៀល សម្រាប់ការ-ដំឡើងរបបសោធនប្រចាំខែទាបបំផុត និង ការកាត់បន្ថយគម្លាតរបបសោធនរបស់និវត្តជនរវាងអ្នកទទួលបានសោធនទាប និង អ្នកទទួលបានសោធនខ្ពស់, និង រវាង និវត្តជនថ្មី និង និវត្តជនចាស់ ។

លើសពីនេះ, ប្រាក់បំណាច់របស់មន្ត្រីជាប់កិច្ចសន្យាក៏នឹងត្រូវបានដំឡើងពីចំនួន ៦០០ ០០០ រៀល នៅ ឆ្នាំ ២០១៨ ដល់ចំនួន ៦៥០ ០០០ រៀល នៅឆ្នាំ ២០១៩ ផងដែរ ។

**ក.១.២-<u>ចំណាយក្រៅបន្ទុកបុគ្គលិក</u>** : មានកំណើន ២២,៨% ធៀបនឹងច្បាប់ឆ្នាំ ២០១៨, ត្រូវជា ៨,១៦% នៃ ផសស, និង មានសមាមាត្រស្មើនឹង ៥៣,៣% នៃចំណាយចរន្តថវិកាថ្នាក់ជាតិ ។

**ក.២- <u>អំពីទិដ្ឋភាពនៃការបែងចែកចំណាយចរន្តថវិកាថ្នាក់ជាតិតាមវិស័យ</u>**

ជារួម, ចំណាយចរន្តថវិកាថ្នាក់ជាតិសម្រាប់ឆ្នាំ ២០១៩ ត្រូវបានវិភាជន៍ដោយផ្អែកលើតម្រូវការ និង អាទិភាពចាំបាច់ រួមទាំងការអនុវត្តនូវកម្មវិធីថ្មីមួយចំនួន ទៅតាមវិស័យធំៗទាំង ៤ រួមមាន ៖ វិស័យសង្គមកិច្ច, វិស័យការពារជាតិ និង សណ្តាប់ធ្នាប់សាធារណៈ, វិស័យរដ្ឋបាលទូទៅ, និង វិស័យសេដ្ឋកិច្ច ហើយដែលអាទិភាពចំណាយសំខាន់ៗ តាមវិស័យនីមួយៗ ក៏មានគូសបញ្ជាក់ពិស្តារនៅក្នុងខ្លឹមសារនៃអត្ថបទសេចក្តីថ្លែងហេតុនៃសេចក្តីព្រាង-ច្បាប់រួចហើយ ដូច្នេះ, ដើម្បីចំណេញពេលបានថែមទៀត, ខ្ញុំបាទសូមមិនអធិប្បាយលម្អិតឡើងវិញទេ, ក៏ប៉ុន្តែ សូមធ្វើការគូសរំលេចដោយខ្លីថា **វិស័យសង្គមកិច្ចនៅតែត្រូវបានចាត់-ទុកជា វិស័យអាទិភាពទី ១** ដោយក្នុងនោះ ការយកចិត្តទុកដាក់ត្រូវបានផ្តោតជាពិសេសលើក្រសួងអាទិភាពចំនួន ៣ គឺ ក្រសួងអប់រំ យុវជន និង កីឡា, ក្រសួងការងារ និង បណ្តុះ-បណ្តាលវិជ្ជាជីវៈ និង ក្រសួងសុខាភិបាល, ព្រមទាំងផ្តោតទៅលើការឆ្លើយតបឱ្យបានសមស្របទៅនឹងអាទិភាព និង គោលនយោបាយថ្មីរបស់រាជរដ្ឋាភិបាលផ្នែកគាំពារសង្គមរួមមានជាអាទិ៍ ៖

*-របបថែទាំសុខភាពសម្រាប់កម្មករ* ៖ បានត្រៀមថវិកាចំនួន ២០ ប៊ីលានរៀល សម្រាប់ពង្រីកវិសាលភាពមូលនិធិសមធម៌ ដើម្បីផ្តល់លទ្ធភាពឱ្យកម្មករ (ទាំងក្នុងប្រព័ន្ធ

និង ក្រៅប្រព័ន្ធ) ដែលមិនទាន់ជាសមាជិករបបសន្តិសុខសង្គម (ប.ស.ស) ទទួលបានរបបថែទាំសុខភាព ដូចប្រជាជនដែលមានប័ណ្ណក្រីក្រដែរ ។

-*របបឧបត្ថម្ភមាតុភាពសម្រាប់កម្មករ* ៖ បានត្រៀមថវិកាចំនួន ៤០ ប៊ីលានរៀល នៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល សម្រាប់បើកផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មការិនី នៅ-ក្រោយពេលសម្រាលកូនរួច តាមការកំណត់របស់រាជរដ្ឋាភិបាល ។

-*ការបន្តនិរន្តរភាពមន្ទីរពេទ្យគន្ធបុប្ផា* ៖ បានគ្រោងថវិកាចំនួន ៤០ ប៊ីលានរៀល សម្រាប់បង្កើន «**មូលនិធិគន្ធបុប្ផាកម្ពុជា**», ព្រមគ្នាជាមួយនឹងការបន្តផ្តល់ថវិកាចំនួន ៤០ ២៥៧ លានរៀល ជូនទៅមន្ទីរពេទ្យគន្ធបុប្ផាដោយផ្ទាល់សម្រាប់ចំណាយប្រតិបត្តិការឆ្នាំ ២០១៩, ដើម្បីធានានិរន្តរភាព គុណភាព និងប្រសិទ្ធភាពរបស់មន្ទីរពេទ្យផង និង ធានាការផ្តល់សេវាដោយមិនយកថ្លៃជូនដល់កុមារនៃគ្រួសារក្រីក្រ ។ ការឧបត្ថម្ភនេះ មិនទាន់គិតបញ្ចូលនូវចំណូល ២ ដុល្លារអាមេរិក ពីទេសចរបរទេសម្នាក់ ពីការលក់សំបុត្រចូលទស្សនាប្រាង្គប្រាសាទក្នុងតំបន់អង្គរ ដែលរាជរដ្ឋាភិបាលបានសម្រេចកាត់យក បង់ដោយត្រង់ទៅជូន **មូលនិធិគន្ធបុប្ផាកម្ពុជា** សម្រាប់ផ្ទេរបន្តជូនទៅមន្ទីរពេទ្យគន្ធបុប្ផា នោះឡើយ ។

-*កម្មវិធីសង្គហទានសង្គមសម្រាប់ស្ត្រីក្រីក្រមានផ្ទៃពោះ និង កុមារតូច រហូតដល់អាយុ ២ ឆ្នាំ* ៖ បានត្រៀមថវិកាចំនួន ២០ ប៊ីលានរៀល នៅក្នុងកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល ។

## ខ- អំពីគម្រោងចំណាយមូលធនថវិកាថ្នាក់ជាតិ

### ខ.១- <u>គម្រោងចំណាយមូលធន</u>

ចំណាយមូលធនថ្នាក់ជាតិត្រូវបានគ្រោងចំនួន ៨ ៩៣៧ ៧៤៨ លានរៀល, សមមូលប្រមាណ ២ ២០៧ លានដុល្លារអាមេរិក, មានកំណើន ៨,៩% ធៀបនឹងច្បាប់ឆ្នាំ ២០១៨, មានសមាមាត្រស្មើនឹង ៣៤,៧% នៃចំណាយថវិកាថ្នាក់ជាតិសរុប, ត្រូវជា ៨,១៣% នៃ ផសស ដែលក្នុងនោះ ៖

*(១)- គម្រោងវិនិយោគផ្ទាល់ដោយហិរញ្ញប្បទានក្នុងប្រទេសនៅថ្នាក់ជាតិ ថយចុះ -៧,៤% ធៀបនឹងច្បាប់ឆ្នាំ ២០១៨ ហើយត្រូវជា ២,៤៦% នៃ ផសស ។ ការថយ-ចុះនេះ គឺដោយសារគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា ប៉ុន្តែចំណាយលើហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលគាំទ្រដល់កំណើនសេដ្ឋកិច្ច និង ភាពប្រកួតប្រជែងកម្ពុជាមិនថយទេ មានន័យថា ថយតែចំណាយវិនិយោគដែលមិនគាំទ្រផ្ទាល់ដល់កំណើនសេដ្ឋកិច្ច ដូចជា អគាររដ្ឋបាល ជាដើម ។*

*(២)- គម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស មានកំណើនត្រឹម ១៧,១% ធៀបនឹងច្បាប់ឆ្នាំ ២០១៨, ត្រូវជា ៤,៨៤% នៃ ផសស ។ ត្រង់នេះ ខ្ញុំបាទសូមគូសបញ្ជាក់ថា* ***ជារួម, ចំណាយថវិកាបានមកពីប្រភពហិរញ្ញប្បទានក្រៅប្រទេស***

*មានទំហំស្មើនឹងប្រមាណជិត ២០% នៃចំណាយថវិកាផ្ទសរុបឆ្នាំ ២០១៩ ប៉ុណ្ណោះ ធៀបនឹងឆ្នាំ ១៩៩៥ ដែលចំណាយបានមកពីប្រភពហិរញ្ញប្បទានក្រៅប្រទេសនេះ មានរហូតដល់ទៅប្រមាណជិត ៧០% នៃចំណាយថវិកាផ្ទសរុប ។ ប្រការនេះ គូស-បញ្ជាក់អំពីភាពកាន់តែឯករាជ្យឡើងជាលំដាប់នៃថវិកាជាតិរបស់កម្ពុជា ។*

ខ.២- ការកំណត់ពិតាននៃការខ្ចីសម្រាប់ឆ្នាំ ២០១៩

បន្ថែមលើអ្វីដែល **ឯកឧត្តម បណ្ឌិតរដ្ឋ ជាម យៀប** បានជម្រាបជូនអំបាញ់មិញ, ខ្ញុំសូមគូសបញ្ជាក់បន្ថែមថា រាជរដ្ឋាភិបាលបានកំណត់ពិដានក្នុងការខ្ចី ក្នុងកម្រិត ១ ៤០០ លានអេសដេអ៊ែរ ក្នុងគោលដៅឆ្លើយតបទៅនឹងសេចក្តីត្រូវការឥណទានយ៉ាងគំហុក និង មានទំហំកាន់តែធំឡើងៗ សម្រាប់ធ្វើហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈ ដែលចេះតែរំកិលពីឆ្នាំមុនៗមក ហើយត្រូវរង់ចាំការចុះហត្ថលេខា ដូចបានរំលេចក្នុងខ្លឹមសារនៃសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់នេះ ។ គម្រោងទាំងនេះ សុទ្ធតែមានចរិតយុទ្ធសាស្ត្រក្នុងការទ្រទ្រង់ដល់ចីរភាពនៃកំណើនសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យម និង វែង ជាពិសេស សម្រាប់ការ-សម្រេចបាននូវគោលដៅក្នុងការកាត់បន្ថយភាពក្រីក្រឱ្យបានយ៉ាងតិច ១% ក្នុងមួយឆ្នាំ ។ យ៉ាងណាក៏ដោយ, ខ្ញុំបាទសូមគូសបញ្ជាក់ថា, ជារួម ការបង្កើនទំហំនៃការខ្ចីនេះនឹងមិនបង្កើតជាបន្ទុកបំណុលវ័ណ្ឌកដល់កម្ពុជាទេ ព្រោះថានៅពេលដែលសេដ្ឋកិច្ចមានការរីកចម្រើននោះសមត្ថភាពសងរបស់កម្ពុជាក៏កើនខ្ពស់ជាងមុនដែរ ។ ជាក់ស្តែង, លទ្ធផលនៃការវិភាគចីរភាពបំណុល ដោយឈរលើមូលដ្ឋានសន្មត់នៃការខ្ចីថ្មីបន្ថែមសម្រាប់ឆ្នាំ ២០១៩ បាន-បង្ហាញឱ្យឃើញថា អនុបាតបំណុលគន្លឹះទាំង ៤ របស់កម្ពុជា សុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់ ដែលជាប្រការបញ្ជាក់ថា ស្ថានភាពបំណុលសាធារណៈរបស់កម្ពុជានៅតែមានចីរភាព និង មានហានិភ័យកម្រិតទាប នៅក្នុងរយៈពេលមធ្យមដដែល ។

## VI- អំពីគម្រោងចំណូល-ចំណាយថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ ២០១៩

**គម្រោងចំណូល-ចំណាយរបស់រដ្ឋបាលរាជធានី-ខេត្ត, ក្រុង-ស្រុក និង ឃុំ-សង្កាត់** មានឱនភាពថវិកាចំនួន ៧៩៩ ៦៦៨ លានរៀល, សមមូលនឹងប្រមាណ ១៩៨ លានដុល្លារអាមេរិក, ហើយដែលត្រូវបានគ្រោងឧបត្ថម្ភដោយថវិកាថ្នាក់ជាតិ **ដែលការឧបត្ថម្ភនេះមានកំណើន ៨,៤% ធៀបនឹងច្បាប់ឆ្នាំ ២០១៨, ត្រូវជា ០,៧៣% នៃ ផសស,** ក្នុងនោះ ឧបត្ថម្ភធនមូលនិធិក្រុង-ស្រុក កើនចំនួន ២៣,៩% និង ឧបត្ថម្ភធនមូលនិធិឃុំ-សង្កាត់ កើនចំនួន ២០,៧% ។

ជាមួយនឹងការបង្កើនចំណាយដើម្បីលើកកម្ពស់គុណភាព និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និង ការអភិវឌ្ឍនៅរដ្ឋបាលថ្នាក់ក្រោមជាតិ, អាទិភាពចំណាយត្រូវបានផ្តល់ដល់ការដំឡើងប្រាក់ឧបត្ថម្ភជូនដល់ ក្រុមប្រឹក្សារាជធានី-ខេត្ត, ក្រុង-ស្រុក-ខ័ណ្ឌ, ឃុំ-សង្កាត់, និង មន្ត្រីភូមិ ផងដែរ ដូចមានគូសរំលេចពិស្តារនៅក្នុងសេចក្តីថ្លែងហេតុ ។

## VII- អំពីតុល្យភាពរួមនៃថវិកាឆ្នាំ ២០១៩

នៅក្នុងក្របខ័ណ្ឌថវិការដ្ឋ ឬ ថវិកាជាតិខាងលើ, ទាំងថវិកាថ្នាក់ជាតិ និង ថវិកាថ្នាក់ក្រោមជាតិ, រាជរដ្ឋាភិបាលអាចរក្សា **អតិរេកថវិកាចរន្ត** ឱ្យបានក្នុងកម្រិតប្រមាណ ២,៨១% នៃ ផសស នៅឆ្នាំ ២០១៩ ធៀបនឹង ២,៤៨% នៃ ផសស គ្រោងក្នុងច្បាប់ឆ្នាំ ២០១៨ នេះ ។ ជាលទ្ធផល, ឱនភាពថវិកាជាតិសរុបនឹងមានទំហំស្មើនឹង -៥,៤៤% នៃ ផសស គឺថយចុះពីកម្រិតនៃឱនភាពគ្រោងក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ ២០១៨ ដែលស្មើនឹង -៥,៨៣% នៃ ផសស ។ ឱនភាពនេះ ត្រូវបានបំពេញបន្ថែមដោយហិរញ្ញប្បទានក្រៅប្រទេសក្នុងទំហំ ៤,៨៤% នៃ ផសស និង មូលនិធិទ្រទ្រង់ថវិកាប្រមាណជា ០,២៣% នៃ ផសស និង ប្រាក់បញ្ញើរាជរដ្ឋាភិបាលក្នុងទំហំ ០,៣៧% នៃ ផសស ស្មើនឹង ៤០៥ ០០០ លានរៀល ឬ សមមូលនឹង ១០០ លានដុល្លារអាមេរិក ដែលត្រូវបានគ្រោងសម្រាប់ផ្តល់ទុនដល់ការបង្កើតធនាគារសហគ្រាសធុនតូច និង មធ្យម (SMEs Bank) របស់រដ្ឋ ដែលទទួលបានការសម្រេចពីរាជរដ្ឋាភិបាលរួចហើយ ។ ដូច្នេះ, **បើមិនគិតអំពីតម្រូវការទុនសម្រាប់បង្កើតធនាគារ SMEs ទេ គឺថវិកាឆ្នាំ ២០១៩ មានតុល្យភាពដោយមិនចាំបាច់ប្រើប្រាក់បញ្ញើ ឬហៅថា "ប្រាក់សន្សំ" របស់រាជរដ្ឋាភិបាលនោះទេ ។**

## VIII - អំពីបញ្ហាប្រឈម និង វិធានការក្នុងការអនុវត្តច្បាប់ថវិកាឆ្នាំ ២០១៩

ការអនុវត្តក្របខ័ណ្ឌថវិកាខាងលើ តម្រូវឱ្យរាជរដ្ឋាភិបាលខិតខំជម្នះនូវការលំបាក និង បញ្ហាប្រឈមមួយចំនួន, ទាំងផ្នែកចំណូល, ទាំងផ្នែកចំណាយ ដូចបានរៀបរាប់លម្អិតនៅក្នុងអត្ថបទសេចក្តីថ្លែងហេតុជូនរដ្ឋសភារួចហើយ ដែលខ្ញុំបាទសូមអនុញ្ញាតមិនអធិប្បាយក្នុងពេលនេះទេ ។

ដើម្បីជម្នះបញ្ហាប្រឈម និង ហានិភ័យនានា ទាំងក្នុងទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច និង ថវិកា ដូចបានគូសបញ្ជាក់ខាងលើ ប្រកបដោយប្រសិទ្ធភាព ព្រមទាំងមានលក្ខណៈជាប្រព័ន្ធ និង ដើម្បីសម្រេចបានតាមគោលដៅនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩, វិធានការដាក់លាក់សម្រាប់ឆ្នាំ ២០១៩ ត្រូវបានដាក់ចេញដូចមានចែងក្នុងអត្ថបទពិស្តារនៃសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់ថវិកានេះ ដែលពាក់ព័ន្ធនឹង ៖ (១)-វិធានការឆ្លើយតបនឹងផលប៉ះពាល់អវិជ្ជមានពីហានិភ័យខាងទិដ្ឋភាពម៉ាក្រូសេដ្ឋកិច្ច; (២)-វិធានការពង្រឹង និង កែលម្អគោលនយោបាយ និង ការគ្រប់គ្រងចំណូល; (៣)-វិធានការពង្រឹង និង កែលម្អគោលនយោបាយ និង ការគ្រប់គ្រងចំណាយ, ទាំងផ្នែករៀបចំ និង ផ្នែកអនុវត្តថវិកា; និង (៤)-ការជំរុញអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ រួមមាន៖ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ-ដំណាក់កាលទី ៣ ជាពិសេស ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់

ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥, ការអនុវត្តកម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ, ការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

## IX - អំពីបទប្បញ្ញត្តិស្តីពីពន្ធដារ

ក្នុងគោលបំណងផ្តល់ភាពងាយស្រួលសម្រាប់អ្នកជាប់ពន្ធ, ទាំងនីតិបុគ្គល និង រូបវន្ត-បុគ្គល, ក្នុងការគណនា និង ការប្រកាសបង់ពន្ធលើប្រាក់ចំណូលរបស់ខ្លួននៅក្នុងឆ្នាំជាប់ពន្ធនីមួយៗ, សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ ក៏បានបញ្ចូលផងដែរនូវ បទប្បញ្ញត្តិស្តីពីពន្ធដារ ចំនួន ២ មាត្រា ។ ខ្ញុំបាទសូមមិនអធិប្បាយលម្អិតលើសំណើវិសោធនកម្មបទបញ្ញប្បញ្ញត្តិស្តីពីពន្ធដារនោះទេ ក៏ប៉ុន្តែសូមអនុញ្ញាតគូសរំលេចវិធានការទាំង ២ ដូចខាងក្រោមៈ

**ទី១. ធ្វើវិសោធនកម្មមាត្រា ៥ នៃច្បាប់ស្តីពីសារពើពន្ធ ស្តីពីនិយមន័យនៃឆ្នាំជាប់-ពន្ធ ដែល «មាត្រា ៥ ថ្មី»** នេះ មានការពន្យល់ច្បាស់លាស់ និង ការញែកឱ្យដាច់ពីគ្នារវាងពន្ធលើប្រាក់ចំណូលរបស់នីតិបុគ្គល និង រូបវន្តបុគ្គល សម្រាប់ឆ្នាំជាប់ពន្ធនីមួយៗ ដែលនឹងផ្តល់ភាពងាយស្រួល ជាពិសេសសម្រាប់រូបវន្តបុគ្គលក្នុងការប្រកាសបង់ពន្ធលើប្រាក់ចំណូលរបស់ខ្លួន ។

**ទី២. ធ្វើវិសោធនកម្ម «មាត្រា ៧ ថ្មី» នៃច្បាប់ស្តីពីសារពើពន្ធ ស្តីពីប្រាក់ចំណូលជាប់ពន្ធ ដែល «មាត្រា ៧ ថ្មី(មួយ)»** នេះ មាន ៤ កថាខណ្ឌ, ហើយដែល កថាខណ្ឌទី ១ ដល់ ទី ៣ មានគោលបំណងបើកផ្លូវឱ្យរាជរដ្ឋាភិបាលចេញអនុក្រឹត្យកំណត់អំពីនីតិវិធី ក្នុងការកាត់កងចំណាយ និង ទាយជ្ជទានសម្រាប់ជាមូលដ្ឋានក្នុងការគណនាប្រាក់ចំណូលជាប់ពន្ធរបស់នីតិបុគ្គល និង រូបវន្តបុគ្គល, និង កថាខណ្ឌទី ៤ កំណត់ឱ្យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចេញប្រកាសណែនាំអំពីវិធាន និង នីតិវិធីនៃការប្រមូលពន្ធ ។

## X - សេចក្តីសន្និដ្ឋាន

ជារួម, ការរៀបចំថវិកាឆ្នាំ ២០១៩ ទោះបីជាជួបប្រទះនឹងបញ្ហាប្រឈម និង ហានិភ័យមួយចំនួនយ៉ាងណាក្តី, ក៏បញ្ហាទាំងអស់ត្រូវបានដោះស្រាយ ហើយថវិកាត្រូវបានវិភាជដោយឈរលើគោលការណ៍ «**ពង្រឹងការគ្រប់គ្រងថវិកា**» សម្រាប់អនុវត្តអាទិភាពគោល-នយោបាយសំខាន់ៗជាសារវ័ន្ត ដែលត្រូវបានកំណត់នៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋា-ភិបាល និង យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា, ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសលើមនុស្ស និង ការកែទម្រង់រចនាសម្ព័ន្ធ ដែលមានអភិបាលកិច្ចជាស្នូល ។

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ, **សូមសម្ដេចអគ្គមហាពញាចក្រី** និង **អង្គសភាទាំងមូល** មេត្តាពិនិត្យ និង ផ្ដល់ការអនុម័តលើ **សេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩** ដោយអនុគ្រោះ ។

*សូមអរគុណ !*